CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៩ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបានចាប់អនុវត្តកម្មវិធីអាហារ 'Great Plates Delivered' សម្រាប់មនុស្សវ័យចំណាស់

*ការផ្តល់អាហារដល់ផ្ទះសម្រាប់បុគ្គលដែលមានអាយុលើសពី ៦៥ ឆ្នាំនិងអ្នកពេញវ័យដែលប្រឈមនឹងហានិភ័យ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចនៅថ្ងៃនេះបានប្រកាសបើកដំណើរការនូវសេវាកម្មដឹកជញ្ជូនអាហារដល់ផ្ទះដោយឥតគិតថ្លៃសម្រាប់មនុស្សវ័យចំណាស់ហើយម្ហូបអាហារគឺផ្តល់ជូនដោយអ្នកផ្តល់អាហារនិងភោជនីយដ្ឋាននៅឡុងប៊ិចដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត COVID-19។ លោកអភិបាលរដ្ឋ Newsom ក្នុងខែមេសាបានប្រកាសពីកម្មវិធីដំបូងបង្អស់នៅក្នុងប្រទេសក្នុងភាពជាដៃគូជាមួយស្រុកក្រុងនិងកុលសម្ព័ន្ធក្នុងកិច្ចប្រឹងប្រែងរក្សាឱ្យប្រជាជនងាយរងគ្រោះបំផុតមានសុខភាពល្អនិងនៅផ្ទះ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងបន្តខិតខំធ្វើការដើម្បីគាំទ្រដល់មនុស្សវ័យចំណាស់របស់យើងក្នុងពេលមានវិបត្តិសុខភាពសាធារណៈនេះ។ យើងសូមថ្លែងអំណរគុណចំពោះអភិបាលរដ្ឋ Newsom និងទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្ននៃសហព័ន្ធដែលបានទទួលស្គាល់ពីតំរូវការដ៏ចាំបាច់នេះនិងធ្វើឱ្យកម្មវិធីនេះធ្វើទៅរួច។"

កម្មវិធីអាហារ Great Plates Delivered នឹងផ្តល់ជូនអាហារបំប៉នដែលមានជីវជាតិដោយឥតគិតថ្លៃរហូតដល់ទៅ ៣ ដងក្នុងមួយថ្ងៃដល់មនុស្សវ័យចំណាស់ដែលមានគុណសម្បត្តិគ្រប់គ្រាន់រហូតដល់ ៦០០ នាក់។ អ្នកផ្គត់ផ្គង់ស្បៀងអាហារនឹងត្រូវទាមទារឱ្យធានានូវគោលការណ៍ណែនាំសុវត្ថិភាពចំណីអាហារឱ្យបានត្រឹមត្រូវហើយសេវាកម្មដឹកជញ្ជូនក៏ដូចជាបុគ្គលដែលនឹងដឹកជញ្ជូនអាហារនឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យប្រវត្តិរូបទាំងអស់។ អាហារនឹងត្រូវដឹកជូនអ្នកចូលរួមដោយសុវត្ថិភាពជារៀងរាល់ថ្ងៃហើយអាចរក្សាទុកបានយ៉ាងងាយស្រួលក្នុងទូទឹកកកឬដាក់ក្នុងកន្លែងកករយៈពេលពីរបីថ្ងៃហើយអាចយកមកកំដៅឡើងវិញ។

**បេក្ខជនត្រូវមានគុណសម្បត្តិដែលបានតម្រូវដូចខាងក្រោម៖**

- រស់នៅទីក្រុងឡុងប៊ិច
- បំពេញតាមតម្រូវការអាយុ៖
    - មានអាយុលើសពី ៦៥ ឆ្នាំ ឬ
    - មានអាយុពី ៦០-៦៤ ឆ្នាំហើយត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាបានឆ្លងឬបានមានការប៉ះពាល់នឹងជម្ងឺ COVID-19 ឬមានហានិភ័យខ្ពស់ដូចដែលបានកំណត់ដោយមជ្ឈមណ្ឌលត្រួតពិនិត្យជំងឺ (CDC)។
- រស់នៅតែម្នាក់ឯងឬជាមួយមនុស្សវ័យចំណាស់ម្នាក់ទៀតដែលមានសិទ្ធិទទួលបានម្ហូបអាហារតាមរយៈកម្មវិធីនេះ
- នៅពេលបច្ចុប្បន្នមិនបានទទួលជំនួយពីកម្មវិធីជំនួយអាហារូបត្ថម្ភរបស់រដ្ឋឬសហព័ន្ធទេ
- មានការលំបាកក្នុងការទទួលបានអាហារឬការរៀបចំអាហារដោយខ្លួនឯង
- ប្រាក់ចំណូលត្រូវតែស្ថិតនៅក្នុងចំនួនដូចខាងក្រោម៖
    - រវាង $24,980 ដុល្លារនិង $74,940 ដុល្លារ (បើតែម្នាក់ឯង) ឬ
    - រវាង $33,821 ដុល្លារនិង $101,460 ដុល្លារ (សម្រាប់គ្រួសារពីរនាក់) ក្នុងមួយឆ្នាំ

ដើម្បីដាក់ពាក្យស្នើសុំអ្នកដែលមានសិទ្ធិត្រូវតែបំពេញពាក្យសុំតាមអ៊ិនធរណេតដោយចូលទៅកាន់គេហទំព័រ LongBeach.gov/seniormealdelivery ឬទូរស័ព្ទទៅលេខ (562) 570-INFO (4636) ហើយជ្រើសរើសយកជម្រើសលេខ ៥។ សំណួរអាចសួរទៅកាន់លេខទូរស័ព្ទដូចគ្នាឬតាមរយៈអ៊ីម៉ែលដោយ

ផ្ញើទៅ GreatPlatesLB@longbeach.gov។ បុគ្គលិកលើកទូរស័ព្ទនឹងឆ្លើយតបនឹងសារដែលបានទុក ហើយអ្នកបកប្រែនឹងមានប្រសិនបើចាំបាច់។

កម្មវិធីអាហារ Great Plates Delivered នឹងដំណើរការរហូតដល់ថ្ងៃទី ១០ ខែមិថុនាឆ្នាំ ២០២០ ដែលកុងពេលបច្ចុប្បន្នគឺជាពេលវេលាដែលបានអនុម័តដោយទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្ននៃសហព័ន្ធ។ រដ្ឋាភិបាលមានបំណងស្នើសុំពន្យារពេលកម្មវិធីនេះដល់ខែកក្កដា។

អាហារបានរៀបចំដោយអ្នកផ្គត់ផ្គង់ម្ហូបអាហារជាច្រើនប្រភេទដែលបានធ្វើកិច្ចសន្យាជាមួយទីក្រុងតាមរយៈដំណើរការដេញថ្លៃកាលពីដើមខែនេះ។ អ្នកដែលចូលរួមផ្តល់អាហាររួមមាន៖

- 5000 Pies
- Bahn Thai Restaurant
- Bebot Filipino Soul Food
- Egg Heaven Cafe
- El Paisa Restaurant
- Hamburger Mary's Long Beach
- La Guanaquita Restaurant
- Michael's Pizzeria Downtown
- ONell's Comfort Kitchen
- Pier 76
- Restauration
- Starling Diner
- Taboon Mediterranean
- TGIS Catering Services
- The 908
- The Little Brass Café Express

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #